ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ :...០១.....ដនស/អកគដ/សរណន

# សារាចរណែនាំ

## ស្តីពី

## ការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ

អនុលោមតាមអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ ៤៨ អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដូចតទៅ :

### ១-វិសាលភាពនៃការអនុវត្ត

សារាចរណែនាំនេះ អនុវត្តសំរាប់ការចុះបញ្ជីអគារ និងក្បាលដីសហកម្មសិទ្ធិ តាមនីតិវិធីនៃការចុះបញ្ជីដីធ្លី ដែលមានចែងក្នុងអនុក្រឹត្យលេខ ៤៦ អនក្រ/បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ ៤៨ អនក្រ/បក ចុះថ្ងៃទ ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

សារាចរណែនាំនេះមានវិសាលភាពគ្របដណ្តប់លើ ÷

- ក្បាលដី និងអគារដែលមានតែជាន់ផ្ទាល់ដី ហើយមានកម្មសិទ្ធិករច្រើន បែងចែកជាចំណែកឯកជន
- ក្បាលដី និងអគារច្រើនជាន់ ដែលមានជណ្តើររួម ទីធ្លារួម និងផ្លូវរួមនាំទៅដល់ចំណែកឯកជននានា
- ក្បាលដី ដែលមានអគារច្រើនដាច់ៗពីគ្នា និងមានកម្មសិទ្ធិករជាច្រើនបានរស់នៅទីនោះ
- ក្បាលដី និងអគារដែលពីមុនមានម្ចាស់តែមួយ តែក្រោយមកមានការលក់ចំណែកមួយ ឬ ចំណែកច្រើនទៅឱ្យភាគីផ្សេងទៀត។

### ២-និយមន័យពាក្យសំខាន់ៗទាក់ទងនឹងសហកម្មសិទ្ធិ

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ ÷

- "អគារសហកម្មសិទ្ធិ" សំដៅដល់អគារគ្រប់ប្រភេទ ដូចជាភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ឬផ្ទះប្រភេទផ្សេងទៀត ដែលមានរចនាសម្ព័ន្ធជាប់គ្នា ដូចជាគ្រឹះក្រោមដីជាប់គ្នា ធ្នឹមជាប់គ្នា លូបង្ហូរទឹករួមគ្នា ជញ្ជាំងរួម ជណ្តើររួម រានហាល និងទោរ៉ាស់រួម ហើយមានកម្មសិទ្ធិករច្រើន។
- "ចំណែកឯកជន" សំដៅដល់ចំណែកនៃអគារ និងដីដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់ជាឯកជន។